# តើអ្វីទៅជាភាពខុសគ្នារវាង ដូសជំរុញ និងដូសទី 3?

## ដូសជំរុញ

អ្នកដែលមានសិទ្ធិទទួលបានវ៉ាក់សាំង អាចជ្រើសរើសវ៉ាក់សាំងណាមួយដែលពួកគេទទួលជាដូសជំរុញ។ គេអាចទទួលប្រភេទវ៉ាក់សាំងជំរុញដូចគ្នា ឬខុសគ្នាពីវ៉ាក់សាំងដែលបានទទួលកាលពីដំបូង។ ឥឡូវនេះ ការណែនាំរបស់ CDC អនុញ្ញាតឲ្យទទួលវ៉ាក់សាំង ជំរុញដោយប្រើប្រភេទចម្រុះ និងវ៉ាក់សាំងដដែល។

### Pfizer និង Moderna

ទី 1 ដូស → 21-28 ថ្ងៃ → ទី 2 ដូស → 6 ខែ → ជំរុញ

វ៉ាក់សាំងជំរុញសម្រាប់បង្ការជំងឺ COVID-19 មានផ្តល់ជូនសម្រាប់អ្នកទទួល វ៉ាក់សាំងដែលបានចាក់វ៉ាក់សាំងដំបូងរួចយ៉ាងតិច 6 ខែកន្លងទៅ និងអ្នកដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ៖

### Johnson & Johnson

ទី 1 ដូស → 2 ខែ → ជំរុញ

វ៉ាក់សាំងជំរុញសម្រាប់បង្ការជំងឺ COVID-19 មានផ្តល់ជូនសម្រាប់អ្នកទទួលវ៉ាក់សាំងដែលបានចាក់វ៉ាក់សាំង Johnson & Johnson រួចយ៉ាងហោចណាស់ 2 ខែកន្លងទៅ និងត្រូវមានអាយុចាប់ពី 18 ឆ្នាំឡើង។

## ដូសទី 3 ដូសបន្ថែមសម្រាប់អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ

ទី 1 ដូស → 21-28 ថ្ងៃ → ទី 2 ដូស → 28 ថ្ងៃ → ទី 3 ដូស → 6 ខែ → ជំរុញ

ដូសទី 3 ត្រូវបានណែនាំសម្រាប់បុគ្គលដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយពីមធ្យមទៅធ្ងន់ - ដែលវ៉ាក់សាំងដំបូងរបស់ពួកគេ គឺជាប្រភេទវ៉ាក់សាំងត្រូវចាក់ 2 ដូស (Pfizer ឬ Moderna) ដើម្បីជំរុញភាពស៊ាំរបស់ពួកគេឆ្លើយតបទៅនឹងវ៉ាក់សាំង។ ដូសជំរុញអាចត្រូវបានផ្តល់ជូនក្នុងរយៈពេលប្រាំមួយខែ ក្រោយពីការទទួលដូសទី 3 ។

**ស្វែងរកវ៉ាក់សាំងបង្ការជំងឺ COVID-19 ៖** វ៉ាក់សាំងមានគ្រប់គ្រាន់សម្រាប់ផ្តល់ជូននៅទូទាំងខោនធី Orange ហើយមានវិធីសាស្រ្តជាច្រើនដើម្បីស្វែងរកការណាត់ជួបដែលងាយស្រួលសម្រាប់អ្នក។ សូមទៅឱសថស្ថាន ឬអ្នកផ្តល់សេវាថែទាំសុខភាពតាមមូលដ្ឋានរបស់អ្នក ឬចូលទៅអ៊ីនធឺណិតតាមគេហទំព័រ Vaccines.gov, MyTurn.ca.gov ឬ Othena.com ដើម្បីកំណត់ពេលណាត់ជួបចាក់វ៉ាក់សាំង។

OC health CARE AGENCY



ទទួលព័ត៌មានលម្អិតបន្ថែមអំពីវ៉ាក់សាំងជំរុញ និងដូសទីបីដោយប្រើប្រាស់កូដ QR ខាងក្រោម៖

សម្រាប់ព័ត៌មានបន្ថែមស្តីពីកន្លែងស្វែងរកវ៉ាក់សាំងបង្ការជំងឺ COVID-19 សូមចូលទៅគេហទំព័រ COVIDVaccineFacts.com ឬចុចកូដ QR ៖

គិតត្រឹម 9/11/21 តទៅ